


# ព្រះភិក្ខុ ធម្មបាល **ខៀវ**-ជុំ

(១៩០៧ - ១៩៧៥)

រៀបរៀងដោយ

បណ្ឌិតសភាចារ្យ **ឃីង ហុកឌី**

កើតរវាងឆ្នាំ១៩០៧[1] នៅ ស្រុងស្អាង ក្នុងខេត្ត កណ្ដាល ក្នុងគ្រួសារកសិករ។[2] កុមារ**ខៀវ**-ជុំបានបួសរៀនហើយបានមកសំណាក់

[1] សូមអានបន្ថែម CORFIELD Justin & SUMMERS Laura, *Historical Dictionary of Cambodia*, The Scarecrow Press, Inc., Lanham, Maryland, and Oxford, 2003,

នៅវត្តគឺ ក្នុងវត្តលង្កានាទីក្រុងភ្នំពេញដោយមាន ឧបជ្ឈាយាចារ្យ ព្រះធម្មលិខិត វជិរប្បញ្ញោ **ល្វា-ឯម** ជាចៅអធិការវត្ត[3]

---

p. 210: “ KHIEU CHUM (c1915-1975)”. ក្នុងកំណត់នេះ បង្ហាញថា ព្រះភិក្ខុ ខៀវ-ជុំកើតនាឆ្នាំ១៩១៥។ យើងយកកាលបរិច្ឆេទកំណើតលោកតាមបញ្ជីព្រះសង្ឃក្នុងពជាគណៈ គឺ ឆ្នាំកំណើតលោកនៅរវាង១៩០៧ ព្រោះលោកជាព្រះសង្ឃដែលមានព្រះជន្មស្របាលៗ នឹងព្រះភិក្ខុប៉ាងខាត់ដែលលោកកើតរវាង ឆ្នាំ១៩១០។

[2] *Harris, Ian (2013). Kings and the Rebellious Monks: Buddhism and Political Conflict in Cambodia. Southeast Asia Seminar Series, Asian Institute, University of Toronto. Retrieved 30 May 2014; Harris, Ian (2010). Buddhism as an Element in Cambodian Political Conflict: the Overthrow of Norodom Sihanouk* (PDF)*. Religious Dimensions to Southeast Asian Conflicts Panel, EUROSEAS Conference, University of Gothenburg. Retrieved 30 May 2014.*

[3] 

បណ្ណាការឧទ្ទិស

ចំណែកនៃសេចក្ដីល្អរបស់សៀវភៅនេះទាំងអស់ ; ខ្ញុំសូមបង្អោនចិត្តលើកឡើងជាកុសល ឧទ្ទិសប្រគេនសម្ដេចព្រះធម្មលិខិត វជិរប្បញ្ញោ, អតីតចៅអធិការវត្តលង្កា, ចាងហ្វាងពុទ្ធិកវិទ្យាល័យ, អធិបតីក្រុមជំនុំប្រែព្រះត្រៃបិដក, សម្ដេចជាព្រះឧបជ្ឈាយ៍របស់ខ្ញុំ, ព្រះអង្គមានព្រះគុណលើខ្លួនខ្ញុំ និងពុទ្ធបរិស័ទទូទៅក្នុងកម្ពុជប្រទេស ។

ខៀវ-ជុំ

*នេះជាបុព្វវាចា ភិក្ខុ ខៀវជុំក្នុងសៀវភៅវេយ្យាករណ៍យើង, ភ្នំពេញ, ១៩៦៦, ទំព័រដើម។*

លង្កាជំនាន់នោះ។ ភិក្ខុខៀវ-ជុំ បានទទួលនាមប្បញ្ញត្តិ ជាសាមណេរ ថាព្រះធម្មបាលោ មានន័យថា ជា « ឆ្នាំព្រះធម៌ »។ រវាងឆ្នាំ១៩៣០ ព្រះសង្ឃរាជគណៈមហានិកាយ ហួត-តាត បានតែងតាំងព្រះភិក្ខុ ខៀវ-ជុំ ជាចៅអធិការវត្តលង្កា ហើយលោកបានកាន់កាប់វត្តនេះ រហូតដល់ឆ្នាំ១៩៧៥ ក្នុងពេលដែល ខ្មែរក្រហមចូលកាន់ទីក្រុងភ្នំពេញ។

នៅឆ្នាំ១៩៤២នាថ្ងៃទី២០កក្កដាព្រះភិក្ខុខៀវ-ជុំ បានចូលរួមជាមួយព្រះសង្ឃនិងគ្រហស្ថមួយចំនួនធ្វើបាតុកម្ម ប្រឆាំងនឹងអាជ្ញាធរបារាំង ដែលអ្នកប្រវត្តិសាស្ត្រអ៊ឺរ៉ុប បានឲ្យឈ្មោះថា៖« សង្គ្រាមឆ័ត្រព្រះសង្ឃ» (« Manifestation ou révolte des ombrelles des bonzes ») ។ ព្រះភិក្ខុធម្មបាលោខៀវ-ជុំជាក្រុមយ៉ាងជិតស្និទ្ធនឹងព្រះអាចារ្យហែម-ចៀវដោយទទួលមនោគមវិជ្ជាព្រះគ្រូអាចារ្យនេះទាំងស្រុង។ ព្រះអង្គជាព្រះសង្ឃជឿនលឿននិយមមួយអង្គដែលគាំទ្រគំនិតលោកសឺង-ង៉ុកថាញ់ ពោលគឺលោកចង់បានឯករាជភាពឲ្យប្រទេសកម្ពុជា។ ហេតុនេះហើយ បានជាអាជ្ញាធរបារាំងចាប់លោកដាក់ពន្ធនាគារជាមួយព្រះសង្ឃមួយចំនួន ដូចជាព្រះភិក្ខុប៉ាងខាត់, ហែមចៀវ...និងអ្នកទោសនយោបាយ មួយចំនួនទៀតដូចជា លោកប៉ាច-ឈឺន, ប៊ុណ្ណចន្ទ-ម៉ុល, ជុំ-មួង, នួន-ឌួង ជាដើម។ បន្ទាប់មកទៀត អាជ្ញាធរបារាំងបានបញ្ជូនអ្នកទោសនយោបាយទាំងអស់នោះ ទៅដាក់ពន្ធនាគារដែលមានទីតាំង ដាច់ស្រយាលឆ្ងាយពីប្រទេសកម្ពុជាគឺនៅ **កោះ ត្រឡាច**។[4]

---

[4] សូមអានបន្ថែម អិនទែណែត៖ http://www.digplanet.com/wiki/Khieu_Chum

**Khieu Chum** (Khmer: ខៀវ ជុំ [kʰiəw cum], 1907-1975) was a prominent Cambodian Buddhist monk and activist who was a member of a small group of

នាចុងសង្គ្រាមលោកលើកទី២ គឺក្នុងឆ្នាំ១៩៤៥ អ្នកទោសនយោបាយទាំងឡាយបានរួចខ្លួនចេញពីគុកកោះត្រឡាច។ ភិក្ខុខៀវ-ជុំនាពេល ដែលបានរួចពីពន្ធនាគារកោះស្រឡាចមកក៏ត្រឡប់ វិល មកគង់នៅវត្តលង្កាជាព្រះសង្ឃដូចដើមវិញ ។

ក្នុងឆ្នាំ១៩៧០ នាពេលដែល ព្រះរាជាណាចក្រកម្ពុជាបាន ប្ដូររបបដឹកនាំប្រែក្លាយទៅជារបប**សាធារណរដ្ឋ**ខ្មែរវិញ គ្រប់គ្រងដោយឧត្តមសេនីយ**លន់នល់**និងទ្រង់**ស៊ីសុវត្ថិសិរិមតៈ**ដែលមាន ព្រះភិក្ខុធម្មបាលោ និងបញ្ញាជនមួយចំនួនជាអ្នកគាំទ្រយ៉ាង ពេញទំហឹង នូវរបប គ្រប់គ្រងថ្មីនេះ។[5]

ព្រះភិក្ខុ ខៀវ-ជុំបានទុកស្នាដៃសំខាន់ៗដូចមានខាងក្រោមនេះ៖

១) ***កម្ពុជវេយ្យាករណ៍***,បោះពុម្ពផ្សាយដោយភិក្ខុធម្មបាលោ ខៀវ-ជុំ,នៅវត្តលង្កាក្រុងភ្នំពេញ,ពស២៥០៤,គស១៩៦២,១២៥២ ទំព័រ។ <u>បណ្ណាល័យឯកជន</u>។

---

people responsible for planning the Cambodian coup of 1970 which overthrew the monarchy and placed General Lon Nol as leader of a new Khmer Republic. Chum was a student of Hem Chieu, a leading figure in the early period of modern Khmer nationalism. After Cambodia achieved independence in 1953, Chum became an active figure in internal politics and is now considered one of the country's most significant political thinkers of the era. He is also credited with writing the Anthem of the Khmer Republic. សូមអានបន្ថែមសៀវភៅលោក ប៉ុណ្ណ-ចន្ទម៉ុល, *គុកនយោបាយ*, ភ្នំពេញ, ១៩៧១។

[5] « Though a « political » monk of immense historical importance, his conservative doctrinal outlook was out of step with Lon Nol’s more radical and mythical sense of Buddhism as a moral force in politics. He opposed the president’s use of Buddhism in official republican ideology. Widely regarded as “Thanhist”, Chum was among the many intellectuals executed in April 1975 for alleged “CIA” sympathies and “enemy” activities.” CORFIELS & SUMMER, *op. cit.*, p. 210.

២) ***វេយ្យាករណ៍យើង***,សម្រាប់បឋមសិក្សាបឋមភូមិ អាទិកដ្ឋាន, បោះពុម្ពផ្សាយដោយទៀន-ហុង-សេង, ក្រុងភ្នំពេញ, ១៩៦៦,១៧៦ទំព័រ។ បណ្ណាល័យឯកជន។

៣) ***ជីវិតតស៊ូ***,ក្រុងភ្នំពេញ,១៩៦៩, ក្រុងភ្នំពេញ ,សូមអាន នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ លេខ២៩៣៨៩១០, ១២២ ទំព័រ។

៤) ***ជីវិតសន្តិភាព***, ក្រុងភ្នំពេញ,២០០១(បោះពុម្ពឡើងវិញ), សូមអាននៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ លេខ២៥៧ ១១៣១១៤១១៥។

៥) ***បញ្ហាជីវិត***, ភ្នំពេញ, គ្មានកាលបរិច្ឆេទ (បោះពុម្ពឡើងវិញសម្រាប់ធម្មទាន),១៥៣ ទំព័រ។

សៀវភៅដែលព្រះភិក្ខុធម្មបាល ខៀវ-ជុំ ទុកជាកេរ ឲ្យកូនខ្មែរគឺ សៀវភៅ *កម្ពុជវេយ្យាករណ៍* មាន១២៥២ទំព័រ និង សៀវភៅ*វេយ្យាករណ៍យើង* ដែលមានសារៈប្រយោជន៍ណាស់ សម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយដោយលោកបានផ្តល់គំនិតថ្មី បែបទំនើបនិយមដែលនាំឲ្យអ្នកឯកទេសខាងភាសាវិទ្យាខ្មែរ អាចយកមកសិក្សាបន្ថែមនិងយកមកត្រិះរិះបន្ត។ ព្រះភិក្ខុធម្មបាលោជាភាសាវិទូ គម្រូ ចំពោះអ្នកសិក្សាភាសាខ្មែរបច្ចុប្បន្នឲ្យមានចក្ខុវិស្ស័យចម្រើននិយមដូចមានអ្នកប្រាជ្ញមុនៗ ខ្លះៗដូចជាលោក

**អៀវ-កើស**[6] និង សាស្ត្រាចារ្យបណ្ឌិត **កេង-វ៉ាន់សាក់**[7] ជាដើម។

សៀវភៅ៣ទៀតមានលក្ខណៈបែបទស្សនវិជ្ជាអនុវត្តន៍ មានប្រយោជន៍ខ្លាំងក្នុងជីវិតរស់នៅរបស់ពុទ្ធបរិស័ទទាំងឡាយ ហាក់ដូចជាសេចក្តីសម្តែងធម្មទេសនាព្រះធម្មបាលផ្តល់ឲ្យពុទ្ធបរិស័ទ បានយល់ពីបញ្ហាជីវិតលោកិយយើងនេះ។

សំណេរស្រាវជ្រាវនេះទុកជាសេចក្តីឧទ្ទិសចំពោះវិញ្ញាណក្ខន្ធព្រះភិក្ខុធម្មបាល ខៀវ-ជុំ ដែលបានទុកជាកេរចំណេះដឹងដ៏ប្រពៃដល់ជនានុជនជំនាន់ក្រោយសិក្សាស្រាវជ្រាវបន្ត។

កុលឡេស្ទៀង, ថ្ងៃទី៤សីហា២០១៦

---

[6] *អៀវ-កើស, ភាសាខ្មែរ. ការល្បងពិនិត្យដោយរកហេតុផល* La langue cambodgienne (Un essai d’étude raisonnée), *ភ្នំពេញ,១៩៤៧, បោះពុម្ពលោកទី២, ១៩៦៧, ៣៦៧ ទំព័រ* + *តារាងបុព្វបទ និង បទជ្រែក។*

[7] *កេង-វ៉ាន់សាស្ត្រ,មូលភាពនៃការបង្កើតពាក្យថ្មី*(« Principes de création des mots nouveaux »), *ជាភាសាខ្មែរ បារាំង, ភ្នំពេញ, ១៩៦៤, ៦៦២ទំព័រ។*



ព្រះធម្មលិខិត **ល្វី -ឯម**

ជាឧបជ្ឈាយាចារ្យ ព្រះធម្មបាល **ខៀវ-ជុំ**



ព្រះធម្មលិខិត **ល្វា-ឯម** ជាចាងហ្វាងពុទ្ធិកវិទ្យាល័យ, អធិបតីក្រុមជំនុំប្រែព្រះត្រៃបិដក, ព្រះអង្គគង់ឈរជួរទី១ក្បែរ សម្ដេចក្រុមព្រះវរជាតិ**នរោត្តមសុទ្ធារស**( បិតាស្ដេច **នរោត្តមសុរាម្រិត** ), ជួរទី២ខាងស្ដាំព្រះអង្គចាងហ្វាង គឺ ព្រះសុមេធាធិបតី **ជួន-ណាត**។




មន្ត្រីសង្ឃជាន់ខ្ពស់គណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា



ភិក្ខុ ធម្មបាល **ខៀវ ជុំ** ប្រសូត ឆ្នាំ១៩០៧ (ខេត្តកណ្ដាល)
សុគតឆ្នាំ១៩៧៥ ព្រះជន្មាយុ ៦៨វស្សា

*(រូបថតនេះ រក្សានៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ផ្ដល់ដោយលោកសុខនី, នាយកស្ថាប័ននេះ, សូមអរគុណលោក)*




*កម្ពុជវេយ្យាករណ៍, ភ្នំពេញ, ១៩៦២, ១២៥២ទំព័រ។*



វេយ្យាករណ៍យើង
សម្រាប់បឋមសិក្សា បឋមភូមិ អាទិកដ្ឋាន
ដោយ
ភិក្ខុ ធម្មបាលោ ខៀវ - ជុំ
ពុម្ពលើកទី ១. ៣០០០ ចប់



# វេយ្យាករណ៍យើង

សម្រាប់បឋមសិក្សា បឋមភូមិ អាទិកដ្ឋាន

ដោយ

ភិក្ខុ ធម្មបាលោ ខៀវ-ជុំ

វត្តលង្កា ក្រុងភ្នំពេញ សង្កាត់លេខ ៦

បោះពុម្ពផ្សាយ

ដោយ

ទៀង-ហុង-សេង

ព. ស. ២៥០៩

គ. ស. ១៩៦៦

អ្នកនិពន្ធរក្សាសិទ្ធិ

KHING Hoc Dy

វេយ្យាករណ៍យើង, ភ្នំពេញ, ទៀន-ហុង-សេង, ១៧៦ទំព័រ។




ជីវិតតស៊ូ, បោះពុម្ពឡើងវិញ, ២០០៤(បោះទី១៩៦៩), ១២២ទំព័រ។




បញ្ញាជីវិត, ភ្នំពេញ, បោះផ្សាយឡើងវិញសម្រាប់ធម្មទាន, ១៥៣ទំព័រ។